ធ៩-៩៨-៤១៤ ប្រ.ក

# ប្រកាស

# ស្តីពី

# ប្រភពទុនជាប្រាក់បញ្ញើសំរាប់ប្រើប្រាស់ក្នុងស្រុក របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

## សំរេច

**ប្រការ ១ :**

ដាក់ចេញនូវវិធានការទប់ស្កាត់ការបញ្ចេញទៅក្រៅប្រទេសនូវប្រភពទុនជាប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានក្នុងស្រុករបស់គ្រឹះស្ថានធនាគារ (ធនាគារពាណិជ្ជ) និងគ្រឹះស្ថានហិរញ្ញវត្ថុក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដើម្បីធានាអោយសញ្ច័យក្នុងស្រុកអាចបំរើផ្នែកវិនិយោគក្នុងប្រទេសបានទាំងស្រុង ។

**ប្រការ ២ :**

រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវរក្សាទុកទាំងអស់ (១០០ ភាគរយ) នូវប្រាក់បញ្ញើដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើអន្តរធនាគារ សំរាប់ការប្រើប្រាស់របស់ខ្លួននៅក្នុងប្រទេស ។

សក្ខីកម្មនៃការរក្សាទុកនេះត្រូវបានឆ្លុះបញ្ចាំងដោយចំនួនសរុបនៃខ្ទង់ប្រាក់មួយចំនួននៅខាងទ្រព្យសកម្មនៃតារាងតុល្យការដូចខាងក្រោម :

- សាច់ប្រាក់នៅក្នុងដៃ
- ប្រាក់បញ្ញើនៅធនាគារក្នុងស្រុក
- ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា (ដកចេញនូវប្រាក់ដឹកលំធានាចំនួន ១០ ភាគរយនៃដើមទុន)
- និងប្រាក់អោយខ្ចីចងការ និងបុរេប្រទាន

ជានិច្ចកាល ចំនួនសរុបនេះយ៉ាងហោចណាស់ត្រូវតែស្មើនឹងប្រាក់បញ្ញើសរុបដែលកេណ្ឌប្រមូលបានពីអតិថិជន និងប្រាក់បញ្ញើជាអន្តរធនាគារ ។

**ប្រការ ៣ :**

នៅរៀងរាល់ខែ រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា (នាយកដ្ឋាន ត្រួតពិនិត្យ) នូវតារាងគណនាដែលបានចែងនៅប្រការ ២ ដោយភ្ជាប់ជាមួយរបាយការណ៍ប្រចាំខែ ស្តីពីទ្រព្យសកម្ម និងទ្រព្យអកម្ម (តារាងតុល្យការ) ដែលធ្លាប់ផ្ញើមកជាប្រក្រតី ។

ក្នុងករណីត្រួតពិនិត្យឃើញតារាងគណនានេះមិនឆ្លើយតបតាមលក្ខខណ្ឌដែលកំណត់នៅប្រការ ២ សាមីគ្រឹះស្ថានត្រូវរងការផាកពិន័យចំនួន ១ ភាគរយក្នុងមួយខែ លើចំនួនដែលខ្វះទុកជាការព្រមានលើកដំបូង សំរាប់រយៈពេលមួយខែ ហួសពីនេះត្រូវរងវិធានការធ្ងន់ធ្ងរថែមទៀតតាមករណីជាក់ស្តែង ។

**ប្រការ ៤ :**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន។

**ប្រការ ៥ :**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៨ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៨

**ទេសាភិបាល**

ហត្ថលេខា និងត្រា **ជា ចាន់តូ**